ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..៦៧៤..សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីសិក្សារកដំណោះស្រាយលើដី ផ្ទះ អតីតស្ថានទូតជប៉ុនប្រចាំនៅទីក្រុងភ្នំពេញ

•••

## រាជរដ្ឋាភិបាល

•••

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមសេចក្តីត្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១.-** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងមួយ ដើម្បីសិក្សារកដំណោះស្រាយលើ ដី ផ្ទះអតីតស្ថានទូត នៃប្រទេសជប៉ុននៅភ្នំពេញ មុនឆ្នាំ១៩៧៥ ដែលមានសមាសភាពដូចតទៅ :

១-លោកជំទាវ ស៊ិន ស៊ី អគ្គលេខាធិការរងរាជរដ្ឋាភិបាល ប្រធាន

២-ឯកឧត្តម ហោ សុធន តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣-លោក កាំង លាងខំណន្ទ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤-លោក ឌុល គៀន តំណាងក្រសួងក្រសួងមហាផ្ទៃ សមាជិក

៥-លោក លឹម សំកុល ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

www.pheakdeylaw.com

៦-លោក **សុខ លក្ខិណា** នាយករងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ សមាជិក

**ប្រការ២.-** ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

-សិក្សារកដំណោះស្រាយលើការទាមទារយកវិញរបស់រាជរដ្ឋាភិបាលជប៉ុន នូវដី ផ្ទះអតីតស្ថានទូតទាំង២ ដែលក្នុងនោះមានផ្ទះឯកឧត្តម **ហ៊ឹម ឆែម** និងអាគារការិយាល័យ លិខិតឆ្លងដែនរបស់ក្រសួងមហាផ្ទៃ

-សិក្សាវាយតំលៃលើដី និងសំណង់ផ្ទះ របស់ឯកឧត្តម **ហ៊ឹម ឆែម** និងអាគារការិយាល័យលិខិតឆ្លងដែនរបស់ក្រសួងមហាផ្ទៃ លើតំលៃដែលត្រូវទូទាត់ ដោយពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសំរុះសំរួលជាមួយនិងម្ចាស់កម្មសិទ្ធិ

-ធ្វើការស្ទាបស្ទង់ជាមួយភាគីជប៉ុនអំពីដំណោះស្រាយផ្សេងៗដែលអាចធ្វើការសំរុះសំរួលលើគ្រប់ទិដ្ឋភាព ។

**ប្រការ៣.-** ក្រុមការងារនេះអាចស្នើកិច្ចសហការពីគណៈកម្មការវាយតំលៃ របស់គណៈកម្មាធិការឯកជនភាវូនីយកម្ម និងត្រូវធ្វើរបាយការណ៍ ពីលទ្ធផលនៃការចរចាជាមួយភាគីជប៉ុន និងលើកគំរោងចំណាយ ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសំរេច ។

**ប្រការ៤.-**សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងត្រូវរំសាយជាស្វ័យប្រវត្តិ បន្ទាប់ពីចប់ភារកិច្ច ។

**ប្រការ៥.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអភិបាលរាជធានីភ្នំពេញ និងសាមីជនដែលមានឈ្មោះចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ១ និង ប្រការ៥
- កាលប្បវត្តិ-ឯកសារ

www.pheakdeylaw.com